**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៤៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង មន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ និងបំពេញបន្ថែមមាត្រា៣៤ថ្មីស្ទួន និង មាត្រា៣៩ស្ទួន របស់អនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការៈ

១-លោក ណួយ ជំនាញ អតីតតំណាងអចិន្ត្រៃយ៍រង ឋានៈអគ្គរាជទូត នៃស្ថានតំណាងអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា អមលេខាធិការដ្ឋានអាស៊ាន នៅទីក្រុងហ្សាការតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន

២-លោកស្រី ផុន សុក្របញ្ញា បច្ចុប្បន្នប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន

៣-លោក ឆាយ មករា បច្ចុប្បន្នប្រធាននាយកដ្ឋានអាស៊ីកណ្តាល អាស៊ីខាងត្បូង និងអូសេអានី ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

៤-លោក ហេង ពិសាល បច្ចុប្បន្នប្រធាននាយកដ្ឋានអាស៊ីបូព៌ា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន អាស៊ី-ប៉ាស៊ីហ្វិក

៥-លោកស្រី គឹមសួគ៌ សុវណ្ណារី បច្ចុប្បន្នប្រធាននាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ា ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា

៦-លោក ហួយ សុភាព បច្ចុប្បន្នប្រធាននាយកដ្ឋានអង្គការអន្តរជាតិ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៧-លោក គៀត សត្ថាវ៉ាឌី បច្ចុប្បន្នប្រធាននាយកដ្ឋានអធិការកិច្ចរដ្ឋបាលកណ្តាល ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន

៨-លោក វណ្ណ វិទ្យា បច្ចុប្បន្នប្រធាននាយកដ្ឋានព័ត៌មាន ជាអគ្គនាយករង នៃក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍

៩-លោក ចែម វណ្ណវឫទ្ធិ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ជាប្រធាននាយកដ្ឋានកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន នៃអគ្គនាយកដ្ឋានអាស៊ាន

១០-លោក ឡៅ សុខសំភា បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកិច្ចការព្រំដែន ជាប្រធាននាយកដ្ឋាន កិច្ចការព្រំដែន នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន

១១-លោក ស្រេង សាតារ៉ូ អតីតអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ជាប្រធាននាយកដ្ឋានអាស៊ីកណ្តាល អាស៊ីខាងត្បូង និងអូសេអានី នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

១២-លោក គង់ បញ្ញា បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីបូព៌ា ជាប្រធាននាយកដ្ឋានអាស៊ីបូព៌ា នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

១៣-លោក ខែម រុយហ្សុន អតីតទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ជាប្រធាននាយកដ្ឋានអាមេរិក នៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា

១៤-លោកស្រី រស់ រាសី បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាហ្វ្រិក-មជ្ឈិមបូព៌ា ជាប្រធាននាយកដ្ឋាន អាហ្វ្រិក-មជ្ឈិមបូព៌ា នៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ា

១៥-កញ្ញា ជា សុម៉ាលី អតីតទីប្រឹក្សា នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ជាប្រធាននាយកដ្ឋានអង្គការសហប្រជាជាតិ នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

១៦-លោក ហេង សុភា អតីតទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋទួរគី ជាប្រធាននាយកដ្ឋានអង្គការអន្តរជាតិ នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

១៧-លោក ផៃ គីមឈន បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីបូព៌ា នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ជាប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ

១៨-លោក ខៀវ រីទ្ធិយ៉ា អតីតអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋស៊ែប៊ី ជាប្រធាននាយកដ្ឋានស្រាវជ្រាវ និងវិភាគយុទ្ធសាស្ត្រ នៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ

១៩-លោក អ៊ុច បូរ៉ុ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកិច្ចការសហគមន៍សេដ្ឋកិច្ចអាស៊ាននិងសង្គម-វប្បធម៌អាស៊ាន ជាប្រធាននាយកដ្ឋានភាសាបរទេស នៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ

២០-លោក គីម ងួន បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអធិការកិច្ចរដ្ឋបាលកណ្ដាល ជាប្រធាននាយកដ្ឋានអធិការកិច្ចរដ្ឋបាលកណ្ដាល នៃអគ្គាធិការដ្ឋាន

២១-លោក ងួន វិសុទ្ធ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអធិការកិច្ចស្ថានតំណាងក្រៅប្រទេស ជាប្រធាននាយកដ្ឋានអធិការកិច្ចស្ថានតំណាងក្រៅប្រទេស នៃអគ្គាធិការដ្ឋាន

២២-លោក សុខ ធា បច្ចុប្បន្នអនុប្រធាននាយកដ្ឋានទំនាក់ទំនងដៃគូសន្ទនាអាស៊ាន ជាប្រធាននាយកដ្ឋានព័ត៌មាន

២៣-លោក ទ្រឿង សំគាល់ បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពិធីការ ជាប្រធាននាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ច និងបញ្ហាសកល នៃក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍

២៤-លោក សេង ផាន់ណា ផ្ទេរពីប្រធាននាយកដ្ឋានអង្គសហប្រជាជាតិ មកជាប្រធាននាយកដ្ឋានវិភាគ និងព្យាករណ៍នយោបាយតំបន់ និងពិភពលោក នៃក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ